


# ព្រះគម្ពីរ បរិសុទ្ធ

## គោលជំនឿ៖ ផ្នែកទីបួន

សាឡូមភ្នំពេញ

**និមិត្តរបស់យើង**

យើងចង់ឃើញសិស្សរបស់ព្រះគ្រីស្ទជាច្រើន លើកព្រះនាមទ្រង់ឡើងនៅជុំវិញបល្ល័ង្ក ព្រះជាម្ចាស់ (វិវរណៈ ៧:៥)

**បេសកកម្មរបស់យើង**

ថ្វាយសិរីល្អដល់ព្រះជាម្ចាស់ តាមរយៈការបង្កើតសិស្សដែលទៅបង្កើតសិស្សបន្តទៀត ពីភ្នំពេញ ទៅទូទាំងកម្ពុជា និងរហូតដល់ចុងបំផុតនៃផែនដី (ម៉ាថាយ ២៨:១៨-២០)

# ព្រះគម្ពីរបរិសុទ្ធ

*យើងខ្ញុំជឿថា ព្រះគម្ពីរបរិសុទ្ធ ដែលមាន៦៦កណ្ឌ ជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលព្រះវិញ្ញាណបរិសុទ្ធ បណ្ដាលឲ្យតែងទុកមក ប្រកបដោយពាក្យច្បាស់លាស់ និងគ្មានកំហុសក្នុងភាសាដើម។*

# ព្រះគម្ពីរបរិសុទ្ធមានពេញទៅដោយសិទ្ធអំណាច ហើយគ្រប់គ្រាន់សម្រាប់ធ្វើជាខ្នាតតែមួយគត់ ដែលជាមូលដ្ឋានគ្រឹះនៃជំនឿ និងការអនុវត្តជំនឿរបស់យើង។

# យើងខ្ញុំជឿថា
# ព្រះគម្ពីរបរិសុទ្ធ ដែលមាន៦៦កណ្ឌ



លោកម៉ូសេ
១៤០០ មុន គ.ស
លោកុប្បត្តិ
និក្ខមនំ
លេវីវិន័យ
ជនគណនា
ចោទិយកថា
ម៉ាឡាគី
៤០០ មុន គ.ស
៣៣ គ.ស
៤០០ឆ្នាំនៃភាពស្ងៀមស្ងាត់
សញ្ញាថ្មី
៤៥-៩០ គ.ស

# ជាព្រះបន្ទូលរបស់ព្រះជាម្ចាស់

# ព្រះយេហូវ៉ា «មានបន្ទូល» - ៣៩១៧ ដង

«ព្រះយេហូវ៉ាទ្រង់មានបន្ទូល» - ៣១៤ ដង

«ព្រះបន្ទូលនៃព្រះយេហូវ៉ា» - ៣០២ ដង

# ដែលព្រះវិញ្ញាណបរិសុទ្ធ
# បណ្ដាលឲ្យតែងទុកមក

# ១) ២ពេត្រុស ១:២០–២១ ទំព័រ ១៥៨២

២០ដោយដឹងសេចក្ដីនេះជាមុនដំបូងថា គ្មានពាក្យទំនាយណា
ក្នុងគម្ពីរ ដែលស្រាយបានតាមតែចិត្តនោះឡើយ
២១ដ្បិត
សេចក្ដីទំនាយមិនដែលមក ដោយបំណងចិត្តមនុស្សទេ គឺជា
មនុស្សបរិសុទ្ធរបស់ព្រះ ដែលបានទាយ ដោយសារព្រះ
វិញ្ញាណបរិសុទ្ធទ្រង់បណ្ដាលវិញ ។

# ២) ២ធីម៉ូថេ ៣:១៦–១៧ ទំព័រ ១៥៤៦

១៦គ្រប់ទាំងបទគម្ពីរ គឺជាព្រះទ្រង់បានបញ្ចេញព្រះវិញ្ញាណ
បណ្តាលឲ្យតែងទេ ក៏មានប្រយោជន៍សំរាប់ការបង្រៀន ការ
រំឭកឲ្យដឹងខ្លួន ការប្រដៅដំរង់ នឹងការបង្ហាត់ខាងឯសេចក្តី
សុចរិត ១៧ដើម្បីឲ្យអ្នកសំណប់របស់ព្រះបានគ្រប់លក្ខណ៍
ហើយមានគ្រប់ទាំងចំណេះសំរាប់នឹងធ្វើការល្អគ្រប់មុខ ។

# θεόπνευστος

πᾶσα γραφὴ θεόπνευστος

**Θεό (θεός) = ព្រះជាម្ចាស់**

**Πνευστος (πνέω) = ផ្លុំខ្យល់ដង្ហើម**

«គ្រប់ទាំងបទគម្ពីរ គឺចេញមកដោយព្រះជាម្ចាស់ផ្លុំខ្យល់ដង្ហើម។»

# តាមរបៀបណាខ្លះ?

- ព្រះជាម្ចាស់សរសេរដោយផ្ទាល់ ( និក្ខមនំ ៣១:១៨ )
- ការសរសេរតាមព្រះមានបន្ទូល ( ជាពិសេសកណ្ឌគម្ពីរហោរា )
- ព្រះបន្ទូលព្រះជាម្ចាស់តាមរយៈមាត់មនុស្ស ( ចោទិយកថា ១៨:១៨-២០ )
- ការសរសេររបស់មនុស្ស ( កណ្ឌប្រវត្តិសាស្ត្រ និង សញ្ញាថ្មី )

# ប្រកបដោយពាក្យច្បាស់លាស់

# ៣) ចោទិយកថា ៦:៦–៧ ទំព័រ ២៤៤

៦សេចក្តីទាំងនេះដែលអញបង្គាប់ដល់ឯងនៅថ្ងៃនេះ នោះត្រូវ
នៅជាប់ក្នុងចិត្តឯងចុះ ៧ត្រូវឲ្យប្រិតប្រៀនសេចក្តីទាំងនេះដល់
កូនចៅឯង ព្រមទាំងនិយាយដំណាល ក្នុងកាលដែលអង្គុយ
នៅក្នុងផ្ទះ ហើយដើរតាមផ្លូវ ក្នុងកាលដែលដេក ហើយក្រោក
ឡើងផង

# ៤) ទំនុកដំកើង ១៩:៧ ទំព័រ ៧២៨

...សេចក្ដីបន្ទាល់នៃព្រះយេហូវ៉ាជាពិត ក៏ធ្វើឲ្យមនុស្សខ្លៅល្ងង់មានប្រាជ្ញា

# និងគ្មានកំហុសក្នុងភាសាដើម។

# ៥) ទំនុកដំកើង ១២:៦ ទំព័រ ៧២២

ឯព្រះបន្ទូលនៃព្រះយេហូវ៉ា នោះសុទ្ធស្អាតទាំងអស់ គឺដូចប្រាក់ដែលគេសាកក្នុងបាវធ្វើពីដី ហើយបានសំរងអស់៧ដងផង

# ៦) សុភាសិត ៣០:៥ ទំព័រ ៨៨២

គ្រប់ទាំងព្រះបន្ទូលនៃព្រះ សុទ្ធតែបរិសុទ្ធ ទ្រង់ជាខែល ដល់អស់អ្នកដែលពឹងជ្រកក្នុងទ្រង់

# ព្រះគម្ពីរបរិសុទ្ធមានពេញទៅដោយសិទ្ធអំណាច

# ៧) រ៉ូម ១៣:១ ទំព័រ ១៨៦៦

...ដ្បិតគ្មានអំណាចណាទេ លើកតែមកពីព្រះ គឺព្រះទ្រង់បានតាំងពួកលោកទាំងនោះឲ្យមានអំណាច

ហើយគ្រប់គ្រាន់សម្រាប់ធ្វើជាខ្នាតតែមួយគត់ ដែលជាមូលដ្ឋានគ្រឹះនៃជំនឿ និងការអនុវត្តជំនឿរបស់យើង។

# ៨) យ៉ូហាន ១៧:១៧ ទំព័រ ១៣៩៤

...ឯសេចក្តីពិត គឺជាព្រះបន្ទូលរបស់ទ្រង់

# ៩ ) ២ធីម៉ូថេ ៣:១៦–១៧ ទំព័រ ១៥៤៦

១៦គ្រប់ទាំងបទគម្ពីរ គឺជាព្រះទ្រង់បានបញ្ចេញព្រះវិញ្ញាណ
បណ្តាលឲ្យតែងទេ ក៏មានប្រយោជន៍សំរាប់ការបង្រៀន ការ
រំឭកឲ្យដឹងខ្លួន ការប្រដៅដំរង់ នឹងការបង្ហាត់ខាងឯសេចក្តី
សុចរិត ១៧ដើម្បីឲ្យអ្នកសំណប់របស់ព្រះបានគ្រប់លក្ខណ៍
ហើយមានគ្រប់ទាំងចំណេះសំរាប់នឹងធ្វើការល្អគ្រប់មុខ ។

# ១០) ១យ៉ូហាន ៤:១ ទំព័រ ១៥៨៨

ពួកស្ងួនភ្ងាអើយ កុំឲ្យជឿគ្រប់ទាំងវិញ្ញាណឡើយ ចូរល្បង
វិញ្ញាណទាំងអស់វិញ ដើម្បីឲ្យបានដឹងជាមកពីព្រះ ឬមិនមែន
ដ្បិតមានហោរាក្លែងក្លាយជាច្រើនកើតមកក្នុងលោកីយនេះ
ហើយ

# ១០) ១យ៉ូហាន ៤:២ ទំព័រ ១៥៨៨

២យើងនឹងសំគាល់ព្រះវិញ្ញាណនៃព្រះបានដូច្នេះ គឺអស់ទាំង
វិញ្ញាណណាដែលថ្លែងប្រាប់ថា ព្រះយេស៊ូវគ្រីស្ទបានមកក្នុង
សាច់ឈាម គឺវិញ្ញាណនោះហើយ ដែលមកពីព្រះ

# ១0 ) ១យ៉ូហាន ៤:៦ ទំព័រ ១៥៨៨

៦ឯយើងរាល់គ្នា ជាអ្នកមកពីព្រះវិញ ហើយអ្នកណាដែល
ស្គាល់ព្រះ នោះក៏ស្តាប់យើងខ្ញុំ តែអ្នកណាដែលមិនមកពីព្រះ
ទេ នោះមិនព្រមស្តាប់យើងខ្ញុំឡើយ គឺយ៉ាងនោះឯង ដែល
យើងនឹងស្គាល់វិញ្ញាណនៃសេចក្តីពិត នឹងវិញ្ញាណនៃសេចក្តី
ខុសឆ្គងទៅបាន ។


ព្រះវរបិតា
ព្រះរាជបុត្រា
ព្រះវិញ្ញាណបរិសុទ្ធ
ព្រះ
ជា
ជា
ជា
មិនមែន
មិនមែន
មិនមែន